OREGON DEPARTMENT OF REVENUE

# ការកំណត់អត្តសញ្ញាណជាតិសាសន៍ និងពូជសាសន៍ខ្លួនឯងដោយស្ម័គ្រចិត្ត

ដំណើរការថ្មីមួយ ដែលចាប់ផ្តើមនៅខែមករា ឆ្នាំ 2025 ដែលអ្នកបង់ពន្ធអាចជ្រើសរើសផ្តល់ព័ត៌មានអំពីជាតិសាសន៍ និងពូជសាសន៍របស់ពួកគេទៅក្រសួងចំណូលរដ្ឋ Oregon (Oregon Department of Revenue) នៅពេលពួកគេបំពេញឯកសារប្រកាសពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន។

## តើវាជាអ្វី?

ការកំណត់អត្តសញ្ញាណខ្លួនឯង គឺជាពេលដែលអ្នកបង់ពន្ធជ្រើសរើសផ្តល់ព័ត៌មានអំជាតិសាសន៍ នឹងពូជសាសន៍របស់ពួកគេដល់ទៅក្រសួង Oregon Department of Revenue។

ដើម្បីផ្តល់ព័ត៌មាននេះ អ្នកបង់ពន្ធត្រូវប្រើទម្រង់ដាច់ដោយឡែកដែលរួមបញ្ចូលជាមួយនឹងឯកសារប្រកាសពន្ធលើប្រាក់ចំណូលរបស់រដ្ឋ Oregon។ មនុស្សដែលមិនត្រូវការដាក់ឯកសារប្រកាសពន្ធអាចដាក់ទម្រង់ដាច់ដោយឡែកនៅ Revenue Online។

## ហេតុអ្វីបានជាយើងសួរ?

ចម្លើយរបស់អ្នកចំពោះសំណួរអំពីជាតិសាសន៍ និងពូជសាសន៍នឹងជួយដល់សេដ្ឋកិច្ចវិទូ និងអ្នកស្រាវជ្រាវរបស់រដ្ឋ ក្នុងការវិភាគភាពមិនស្មើគ្នានៅក្នុងគោលនយោបាយពន្ធ។ ការស្រាវជ្រាវរបស់ពួកគេនឹងផ្តល់ព័ត៌មានដល់ការសន្ទនាអំពីគោលនយោបាយពន្ធនាពេលបច្ចុប្បន្ន និងនាអនាគត។

ការចូលរួមរបស់អ្នកបង់ពន្ធទូទាំងរដ្ឋ Oregon គឺមានសារៈសំខាន់ណាស់។ នៅពេលមានអ្នកបង់ពន្ធជ្រើសរើសចែករំលែកព័ត៌មានអំពីជាតិសាសន៍ និងពូជសាសន៍របស់ពួកគេកាន់តែច្រើន ទិន្នន័យស្រាវជ្រាវនឹងកាន់តែត្រឹមត្រូវ។

## អ្នកនឹងសម្រេចចិត្ត។

វាអាស្រ័យទៅលើអ្នកថាតើអ្នកឆ្លើយសំណួរអំពីជាតិសាសន៍ និងពូជសាសន៍ដែរឬអត់។ ទម្រង់បែបបទនេះគឺជាការស្ម័គ្រចិត្ត។ អ្នកមិនតម្រូវឱ្យផ្តល់ចម្លើយចំពោះសំណួរអំពីជាតិសាសន៍ និងពូជសាសន៍ឡើយ។

ក្រសួង Oregon Department of Revenue សង្ឃឹមថា អ្នកនឹងឆ្លើយសំណួរទាំងនេះ ដូច្នេះ វាអាចបម្រើអ្នក និងអ្នករស់នៅរដ្ឋ Oregon ទាំងអស់គ្នាបានកាន់តែប្រសើរ។

## តើអ្នកការពារឯកជនភាពរបស់ខ្ញុំដោយរបៀបណា?

យើងចង់ឱ្យអ្នកគ្រប់គ្នាមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការឆ្លើយសំណួរអំពីជាតិសាសន៍ និងពូជសាសន៍។ ព័ត៌មានរបស់អ្នកត្រូវបានរក្សាការសម្ងាត់ និងការពារយ៉ាងតឹងរ៉ឹង។

យើងនឹងការពារព័ត៌មានរបស់អ្នក ហើយមានតែបុគ្គលដែលមានការអនុញ្ញាតប៉ុណ្ណោះដែលអាចចូលប្រើវាបាន។ យើងនឹងមិនប្រើព័ត៌មានរបស់អ្នកសម្រាប់គោលបំណងផ្សេងទៀតទេ។ ព័ត៌មានអំពីជាតិសាសន៍ និងពូជសាសន៍របស់អ្នកនឹងមិនរួមបញ្ចូលព័ត៌មានអត្តសញ្ញាណផ្ទាល់ខ្លួនណាមួយដូចជាឈ្មោះ អាសយដ្ឋាន ឬលេខទូរសព្ទឡើយ។

អ្នកជំនាញផ្នែកពន្ធដារ និងក្រុមហ៊ុនផ្គត់ផ្គង់សុសវែរពន្ធនឹងមិនប្រើព័ត៌មានរបស់អ្នកសម្រាប់អ្វីផ្សេងក្រៅពីជួយអ្នកក្នុងការបំពេញឯកសារប្រកាសពន្ធរបស់អ្នកទេ។

យើងនឹងមិនចែករំលែកព័ត៌មានរបស់អ្នកជាមួយសេវាកម្មចំណូលផ្ទៃក្នុង (Internal Revenue Service, IRS) ទេ។

**អ្នកអាចទទួលបានឯកសារនេះជាភាសាផ្សេងទៀត អក្សរពុម្ពធំ អក្សរស្ទាបសម្រាប់ជនពិការភ្នែក ឬទម្រង់ដែលអ្នកចូលចិត្តដោយមិនគិតថ្លៃ។**
**ទាក់ទងមកdor.comms@dor.oregon.gov សម្រាប់ការស្នើសុំ**
**របស់អ្នក។**

## ទាក់ទងមកយើងខ្ញុំ

1-800-356-4222 www.oregon.gov/dor